# ព្រះរាជក្រម

នស/រកម/០៦១៨/ ០១១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជាតិរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ចូល
លេខ........
ថ្ងៃទី........ ឆ្នាំ........ ម៉ោង........
បញ្ជូនទៅ........

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា៦ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១១ មាត្រា១២ ចំណងជើងជំពូកទី៤ មាត្រា១៦ មាត្រា១៩ មាត្រា២៦ មាត្រា៥០ មាត្រា៥១ មាត្រា៥២ មាត្រា៥៣ មាត្រា៥៤ មាត្រា៥៥ មាត្រា៥៦ មាត្រា៥៧ មាត្រា៥៨ មាត្រា៥៩ មាត្រា៦៥ មាត្រា៦៦ មាត្រា៦៧ និងមាត្រា៦៨នៃច្បាប់ស្តីពីស្តង់ដារកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាលើកទី១០ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់

## ស្ដីពី

## វិសោធនកម្មមាត្រា៣ មាត្រា៦ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១១ មាត្រា១២ ចំណងជើងជំពូកទី៤ មាត្រា១៦ មាត្រា១៩ មាត្រា២៦ មាត្រា៥០ មាត្រា៥១ មាត្រា៥២ មាត្រា៥៣ មាត្រា៥៤ មាត្រា៥៥ មាត្រា៥៦ មាត្រា៥៧ មាត្រា៥៨ មាត្រា៥៩ មាត្រា៦៥ មាត្រា៦៦ មាត្រា៦៧ និងមាត្រា៦៨ នៃច្បាប់ស្ដីពីស្ដង់ដារកម្ពុជា ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រម

លេខ នស/រកម/០៦០៧/០១៣

ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៧

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រាមួយ ._**

មាត្រា៣ មាត្រា៦ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១១ មាត្រា១២ ចំណងជើងជំពូកទី៤ មាត្រា១៦ មាត្រា១៩ មាត្រា២៦ មាត្រា៥០ មាត្រា៥១ មាត្រា៥២ មាត្រា៥៣ មាត្រា៥៤ មាត្រា៥៥ មាត្រា៥៦ មាត្រា៥៧ មាត្រា៥៨ មាត្រា៥៩ មាត្រា៦៥ មាត្រា៦៦ មាត្រា៦៧ និងមាត្រា៦៨នៃច្បាប់ស្តីពីស្តង់ដារកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

**មាត្រា៣ ._ថ្មី**

លើកលែងតែមានសេចក្តីចែងផ្សេងពីនេះ បណ្តាពាក្យដែលប្រើប្រាស់ក្នុងច្បាប់នេះ មានអត្ថន័យនិងការបកស្រាយដូចខាងក្រោម៖

- ស្តង់ដារ សំដៅដល់ឯកសារដែលត្រូវបានអនុម័តដោយស្ថាប័នមានសមត្ថកិច្ច (recognized body) សម្រាប់ការប្រើប្រាស់ជាទូទៅនិងបន្តបន្ទាប់ ដែលជាវិធាន គោលការណ៍ណែនាំឬចរិតលក្ខណៈសម្រាប់ផលិតផលឬដំណើរការពាក់ព័ន្ធ និងវិធីសាស្ត្រផលិតកម្ម ដែលការអនុលោមមិនមានលក្ខណៈតម្រូវឲ្យអនុវត្តនោះទេ ។ ពាក្យស្តង់ដារនេះអាចរួមបញ្ចូលឬប្រើប្រាស់សម្រាប់តែការតម្រូវផ្នែកវាក្យសព្ទ និមិត្តសញ្ញា ការវេចខ្ចប់ ការធ្វើសញ្ញាសម្គាល់ ឬការធ្វើស្លាកសញ្ញា ដែលអនុវត្តទៅលើផលិតផល ដំណើរការឬវិធីសាស្ត្រផលិតកម្ម។
- ស្តង់ដារនីយកម្ម សំដៅដល់សកម្មភាពនៃការបង្កើតនូវបញ្ញត្តិទាំងឡាយដែលទាក់ទងនឹងបញ្ហាជាក់ស្តែងឬបញ្ហាសំខាន់ៗដើម្បីទុកសម្រាប់ការប្រើប្រាស់ជាទូទៅនិងបន្តបន្ទាប់ សំដៅជានាឲ្យបានដល់ចំណុចប្រសើរបំផុតនៃបរិបទមួយ។ សកម្មភាពខាងលើនេះមានជាអាទិ៍ ដំណើរការនៃការបង្កើត ការចេញ និងការអនុវត្តស្តង់ដារ។
- ស្តង់ដារកម្ពុជា សំដៅដល់ស្តង់ដារដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដារជាតិនិងប្រកាសឲ្យប្រើដោយរដ្ឋមន្ត្រី។
- បទប្បញ្ញត្តិបច្ចេកទេស សំដៅដល់ឯកសារដែលចែងអំពីចរិតលក្ខណៈផលិតផលឬដំណើរការពាក់ព័ន្ធ និងវិធីសាស្ត្រផលិតកម្ម ដោយរួមបញ្ចូលទាំងបញ្ញត្តិរដ្ឋបាលដែលអាចអនុវត្តបាន ដែលការអនុលោមមានលក្ខណៈបញ្ជា។ បទប្បញ្ញត្តិបច្ចេកទេសអាចរួមបញ្ចូលឬប្រើប្រាស់សម្រាប់តែការតម្រូវផ្នែកវាក្យសព្ទ និមិត្តសញ្ញា ការវេចខ្ចប់ ការធ្វើសញ្ញាសម្គាល់ ឬការធ្វើស្លាកសញ្ញា ដែលអនុវត្តទៅលើផលិតផល ដំណើរការ ឬវិធីសាស្ត្រផលិតកម្ម។
- សញ្ញាស្តង់ដារ សំដៅដល់សញ្ញាបញ្ជាក់ផលិតផលឬសញ្ញាបញ្ជាក់ប្រព័ន្ធ។
- សញ្ញាបញ្ជាក់ផលិតផល សំដៅដល់សញ្ញាដែលបញ្ជាក់ពីភាពអនុលោមនៃផលិតផលណាមួយ តាមការតម្រូវនៃស្តង់ដារផលិតផលមួយ មានសញ្ញាបញ្ជាក់ គុណភាព សុវត្ថិភាព ការចុះបញ្ជី ផលិតផល។
- សញ្ញាបញ្ជាក់ប្រព័ន្ធ សំដៅដល់សញ្ញាដែលបញ្ជាក់ពីភាពអនុលោមនៃប្រព័ន្ធមួយទៅតាមការតម្រូវនៃស្តង់ដារជាតិឬស្តង់ដារអន្តរជាតិមួយដែលបានទទួលស្គាល់ ក្នុងនោះមានសញ្ញាបញ្ជាក់ប្រព័ន្ធគ្រប់គ្រងគុណភាព ប្រព័ន្ធគ្រប់គ្រងបរិស្ថាន ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

- អាជ្ញាបណ្ណ សំដៅដល់លិខិតអនុញ្ញាតដែលវិទ្យាស្ថានបានចេញឲ្យតាមការស្នើសុំ ដើម្បីប្រើសញ្ញាស្តង់ដារ។
- ការបញ្ជាក់ សំដៅដល់នីតិវិធីមួយដែលក្នុងនោះ តតិយជនម្នាក់ផ្តល់ការធានាជាលាយលក្ខណ៍អក្សរថាទំនិញ ដំណើរការ ការអនុវត្ត ឬសេវាកម្មសមស្របទៅតាមការតម្រូវដែលបានកំណត់។
- តតិយជន សំដៅដល់អង្គភាពឬបុគ្គលណាមួយដែលទទួលស្គាល់ថាមានភាពឯករាជ្យចំពោះអ្នកផ្គត់ផ្គង់និងអ្នកទិញ។
- ការវាយតម្លៃភាពអនុលោម សំដៅដល់សកម្មភាពណាមួយដែលពាក់ព័ន្ធនឹងការកំណត់ដោយផ្ទាល់ ឬដោយប្រយោលថា ការតម្រូវដែលពាក់ព័ន្ធទាំងឡាយត្រូវបានបំពេញ។
- ការធានាគុណភាព សំដៅដល់សកម្មភាពដែលបានគ្រោងទុកនិងបានរៀបចំជាប្រព័ន្ធគុណភាព ដើម្បីផ្តល់នូវទំនុកចិត្តគ្រប់គ្រាន់ថាផលិតផលឬសេវាកម្មនឹងបំពេញតាមការតម្រូវសម្រាប់គុណភាព។
- ទំនិញ សំដៅដល់របស់របរ ផលិតផលឬជាវត្ថុអ្វីមួយដែលជាកម្មវត្ថុក្នុងការធ្វើពាណិជ្ជកម្ម។
- ក្រុមប្រឹក្សា សំដៅដល់ក្រុមប្រឹក្សាស្តង់ដារជាតិ។
- វិទ្យាស្ថាន សំដៅដល់វិទ្យាស្ថានស្តង់ដារកម្ពុជា។
- អគ្គនាយក សំដៅដល់អគ្គនាយកនៃវិទ្យាស្ថានស្តង់ដារកម្ពុជា។
- មន្ត្រីអធិការកិច្ច សំដៅដល់មន្ត្រីដែលទទួលបាននីតិសម្បទាជា នគរបាលយុត្តិធម៌ ដែលត្រូវចាត់តាំងស្របតាមមាត្រា៧(ថ្មី)នៃច្បាប់នេះ។
- រដ្ឋមន្ត្រី សំដៅដល់រដ្ឋមន្ត្រីដែលទទួលបន្ទុកវិស័យឧស្សាហកម្មនិងត្រួតពិនិត្យមើលលើស្តង់ដារនីយកម្ម និងការធានាគុណភាព។

## មាត្រា៦ ._ថ្មី

វិទ្យាស្ថានស្តង់ដារកម្ពុជា ត្រូវបានដឹកនាំគ្រប់គ្រងដោយអគ្គនាយកមួយរូបដែលមានលក្ខណសម្បត្តិសមស្រប មានសញ្ញាបត្រកម្រិតឧត្តមសិក្សាខាងផ្នែកវិទ្យាសាស្ត្របច្ចេកទេស ព្រមទាំងមានបទពិសោធយ៉ាងតិច៥(ប្រាំ)ឆ្នាំ ក្នុងការងារស្តង់ដារនីយកម្ម។

## មាត្រា៧ ._ថ្មី

មន្ត្រីអធិការកិច្ច ត្រូវតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់នេះ។

មន្ត្រីអធិការកិច្ចទទួលនីតិសម្បទាជា នគរបាលយុត្តិធម៌ ឲ្យពិនិត្យបទល្មើសដែលមានចែងនៅក្នុងច្បាប់នេះ ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ច ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីដែលទទួលបន្ទុកវិស័យឧស្សាហកម្ម។

មន្ត្រីអធិការកិច្ចដែលចុះទៅបំពេញភារកិច្ចក្នុងបរិវេណ ទីតាំង ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងមានសិទ្ធិស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់ថ្នាក់និងអង្គភាពប្រដាប់អាវុធឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដែលមានចែងក្នុងច្បាប់នេះ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់នេះ មន្ត្រីអធិការកិច្ចត្រូវស្លៀកពាក់ឯកសណ្ឋាននិងត្រូវមានលិខិតបញ្ជាបេសកកម្ម។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨ ._ថ្មី**

មន្ត្រីអធិការកិច្ចមានសិទ្ធិ ដូចតទៅ៖

១- អាចចូលក្នុងបរិវេណ ទីតាំងដោយបង្ហាញលិខិតបញ្ជាបេសកកម្ម ដែលចេញដោយវិទ្យាស្ថានដល់អ្នកកាន់កាប់ ដើម្បី៖

ក- ពិនិត្យនិងយកគំរូផលិតផល ឬទំនិញ ឬសម្ភារៈ ឬសារធាតុដែលបានប្រើប្រាស់ឬដែលសង្ស័យថានឹងយកមកប្រើប្រាស់ក្នុងកម្មន្តសាល។

ខ- បើកកញ្ចប់ឬកុងតឺន័រណាដែលមានផ្ទុកឬដែលសង្ស័យថាមានផ្ទុកផលិតផល ឬទំនិញ ឬសម្ភារៈ ឬសារធាតុ៖

- ដែលស្នើសុំអាជ្ញាបណ្ណ ឬ
- ដែលមានប្រើសញ្ញាស្តង់ដារដោយគ្មានអាជ្ញាបណ្ណ ឬ
- ដែលមានអាជ្ញាបណ្ណហើយ តែត្រូវបានសង្ស័យថាបានផលិតឬបានកែច្នៃក្នុងផលិតកម្មដែលមិនអនុលោមទៅតាមស្តង់ដារ ឬបទប្បញ្ញត្តិបច្ចេកទេសពាក់ព័ន្ធ ឬ
- ដែលតម្រូវឲ្យអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស។

២- ត្រួតពិនិត្យការផលិត ឬការកែច្នៃ ឬការនាំចូល ឬការផ្សព្វផ្សាយពាណិជ្ជកម្មលក់ ឬការលក់ផលិតផលណាមួយ ដែលតម្រូវឲ្យអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

៣- តាមដាន ស្រាវជ្រាវ ឆែកឆេរ ចាប់យកផលិតផលឬឧបករណ៍ពាក់ព័ន្ធផ្សេងៗទៀត បិទស្លាកបោះត្រាលើវត្ថុតាងនៃបទល្មើស ឬចាត់វិធានការចាំបាច់នានា ក្នុងករណីដែលមានការសង្ស័យថាមានការល្មើសនឹងច្បាប់នេះ។

៤- តម្រូវឲ្យអាជីវករដែលតម្រូវឲ្យអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសផ្តល់ព័ត៌មាននិងបង្ហាញវិញ្ញាបនបត្របញ្ជាក់ផលិតផល ឬវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ ឬអាជ្ញាបណ្ណ ឬឯកសារដែលពាក់ព័ន្ធក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួន។

៥- កោះហៅជាលាយលក្ខណ៍អក្សរដល់បុគ្គល ដើម្បីមកផ្តល់ចម្លើយឬឲ្យបញ្ជូនឯកសារឬវត្ថុផ្សេងៗដើម្បីធ្វើការពិចារណា។

៦- ចាត់វិធានការហាមឃាត់ជាបណ្តោះអាសន្នចំពោះការផលិតដើម្បីផ្គត់ផ្គង់ចែកចាយឬចរាចរលើទីផ្សារនូវប្រភេទផលិតផលទាំងឡាយណាដែលបានស្រាវជ្រាវឃើញភស្តុតាងថាមិនមានអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេស និងបង្កហានិភ័យក្នុងផលិតកម្មឬបង្កគ្រោះថ្នាក់ចំពោះសុខភាពមនុស្ស សត្វ រុក្ខជាតិ បរិស្ថាន និងសន្តិសុខសង្គម រួចហើយរាយការណ៍យ៉ាងឆាប់តាមដែលអាចធ្វើបានជូនក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីសហការចាត់វិធានការបន្តតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

៧- ដកយកសំណាកផលិតផលដែលជាកម្មវត្ថុនៃការត្រួតពិនិត្យនិងការធ្វើវិភាគផ្ទៀងផ្ទាត់ភាពអនុលោមតាមស្តង់ដារនិងបទប្បញ្ញត្តិបច្ចេកទេស។

៨- ព្យួរ ដកហូត ឬលុបចោលនូវវិញ្ញាបនបត្របញ្ជាក់ផលិតផល ឬវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ ឬអាជ្ញាបណ្ណ ឬឯកសារដែលពាក់ព័ន្ធ ក្នុងករណីដែលម្ចាស់កាន់កាប់វិញ្ញាបនបត្របញ្ជាក់ផលិតផល ឬវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ ឬអាជ្ញាបណ្ណនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ។

បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៩ ._ថ្មី**

នៅក្នុងដំណើរការត្រួតពិនិត្យ ក្នុងករណីមានភស្តុតាងជាក់ស្តែងឬលទ្ធផលវិភាគផ្ទៀងផ្ទាត់បញ្ជាក់ថាផលិតផលណាមួយមិនអនុលោមតាមស្តង់ដារឬបទប្បញ្ញត្តិបច្ចេកទេស មន្ត្រីអធិការកិច្ចមានសិទ្ធិចាត់វិធានការផ្អាកជាបណ្តោះអាសន្នមិនឱ្យផ្គត់ផ្គង់ចែកចាយផលិតផលទាំងនោះឬតម្រូវឱ្យរូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលខុសត្រូវលើផលិតផលនោះប្រមូលបញ្ចូលឃ្លាំងវិញ ដើម្បីដោះស្រាយតាមនីតិវិធី។

បុគ្គលណាដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ច អាចធ្វើបណ្តឹងតវ៉ាក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ទៅរដ្ឋមន្ត្រី គិតចាប់ពីថ្ងៃបានទទួលសេចក្តីសម្រេច។

រដ្ឋមន្ត្រីត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

ក្នុងករណីបុគ្គលនោះមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី ជននោះមានសិទ្ធិធ្វើបណ្តឹងទៅតុលាការតាមនីតិវិធី។

នៅពេលប្រតិបត្តិការអនុវត្តច្បាប់នេះ ក្នុងករណីដែលវត្ថុតាងនៃបទល្មើសជាផលិតផលមានគ្រោះថ្នាក់ មន្ត្រីអធិការកិច្ចមានសិទ្ធិស្នើសុំដីកាសម្រេចរបស់ព្រះរាជអាជ្ញា ដើម្បីធ្វើការកម្ទេចចោល ដោយអនុលោមតាមនីតិវិធីជាធរមាន។

ចំណាយលើសំណាកនិងសេវាកម្មវិភាគសំណាកផលិតផល ចំណាយលើការលើកដាក់ ដឹកជញ្ជូន ការថែរក្សា និងការបំផ្លាញចោលវត្ថុតាងនៅក្នុងដំណើរការអនុវត្តច្បាប់នេះ គឺជាបន្ទុករបស់ម្ចាស់វត្ថុតាងនៃបទល្មើស។ ករណីអត្តសញ្ញាណម្ចាស់វត្ថុតាងនៃបទល្មើសមិនត្រូវបានស្គាល់ រាល់ចំណាយជាបន្ទុករបស់រដ្ឋ។

បុគ្គលគ្រប់គ្រងក្នុងបរិវេណ ទីតាំង ត្រូវបង្កលក្ខណៈងាយស្រួលដល់មន្ត្រីអធិការកិច្ចគ្រប់ពេលក្នុងការចូលបំពេញភារកិច្ចក្នុងបរិវេណទីតាំងរបស់ខ្លួន។

មន្ត្រីអធិការកិច្ចមានកាតព្វកិច្ចរក្សាការសម្ងាត់នូវរាល់ព័ត៌មានដែលខ្លួនទទួលបាននៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន លើកលែងតែ៖

- មានការតម្រូវពីរដ្ឋមន្ត្រីឬពីតុលាការ
- ដើម្បីអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះឬច្បាប់ផ្សេងទៀត។

**មាត្រា១១ ._ថ្មី**

ក្រុមប្រឹក្សាស្តង់ដារជាតិមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីទទួលបន្ទុកវិស័យឧស្សាហកម្ម | ជាប្រធាន |
| - អគ្គនាយកនៃវិទ្យាស្ថានស្តង់ដារកម្ពុជា | ជាអនុប្រធានអចិន្ត្រៃយ៍ |
| - តំណាងក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| - តំណាងក្រសួងការពារជាតិ | ជាអនុប្រធាន |
| - តំណាងក្រសួងពាណិជ្ជកម្ម | ជាអនុប្រធាន |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាអនុប្រធាន |
| - តំណាងក្រសួងសុខាភិបាល | ជាអនុប្រធាន |
| - តំណាងក្រសួងបរិស្ថាន | ជាសមាជិក |
| - តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន | ជាសមាជិក |
| - តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាសមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| - តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ជាសមាជិក |
| - តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាសមាជិក |
| - តំណាងក្រសួងទេសចរណ៍ | ជាសមាជិក |
| - តំណាងក្រសួងរ៉ែនិងថាមពល | ជាសមាជិក |
| - តំណាងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ជាសមាជិក |
| - តំណាងរាជបណ្ឌិត្យសភាកម្ពុជា | ជាសមាជិក |
| - តំណាងសកលវិទ្យាល័យភូមិន្ទភ្នំពេញ | ជាសមាជិក |
| - តំណាងសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | ជាសមាជិក |
| - តំណាងសកលវិទ្យាល័យភូមិន្ទកសិកម្ម | ជាសមាជិក |
| - តំណាងសភាពាណិជ្ជកម្មកម្ពុជា | ជាសមាជិក |
| - តំណាងសមាគមអ្នកផលិត | ជាសមាជិក |
| - តំណាងសមាគមអ្នកប្រើប្រាស់ | ជាសមាជិក |
| - តំណាងក្រសួងស្ថាប័នផ្សេងទៀតតាមការចាំបាច់ | ជាសមាជិក។ |

ឈ្មោះប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យឧស្សាហកម្ម។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

សមាជិកក្រុមប្រឹក្សាមានអាណត្តិ៣(បី)ឆ្នាំនិងអាចត្រូវបានតែងតាំងជាថ្មីសម្រាប់រយៈពេលបន្តទៀត លើកលែងតែក្នុងករណីលាលែង ឬបោះបង់ចោលតំណែង ឬដកហូតតំណែង។

សមាជិកនៃក្រុមប្រឹក្សាត្រូវមានលក្ខណសម្បត្តិដូចតទៅ៖

មានសញ្ជាតិខ្មែរ

មិនដែលមានទោសពីបទឧក្រិដ្ឋឬមជ្ឈិមណាមួយ

មានសញ្ញាបត្រកម្រិតឧត្តមសិក្សាក្នុងផ្នែកវិទ្យាសាស្ត្រឬវិស្វកម្ម និង

មានបទពិសោធការងារយ៉ាងតិច៥(ប្រាំ)ឆ្នាំ។

**មាត្រា១២ ._ថ្មី**

ក្រុមប្រឹក្សាស្តង់ដារជាតិមានភារកិច្ចដូចខាងក្រោម៖

ក- សម្រេចយល់ព្រម កែសម្រួល ឬលុបចោលស្តង់ដារជាតិណាមួយ។

ខ- សម្រេចយល់ព្រម កែសម្រួល ឬលុបចោលសញ្ញាស្តង់ដារណាមួយ។

គ- កំណត់អំពីស្តង់ដារស្ម័គ្រចិត្ត ឬបទប្បញ្ញត្តិបច្ចេកទេស ឬសញ្ញាស្តង់ដារ។

ឃ-ជូនយោបល់ដល់រដ្ឋមន្ត្រីអំពីអាទិភាពនិងគោលនយោបាយនៃស្តង់ដានីយកម្ម កម្មវិធី ផែនការ គម្រោង និងសកម្មភាពនានា ដើម្បីធានាឲ្យមានប្រសិទ្ធភាពខ្ពស់បំផុត។

ង- ជូនយោបល់និងលើកអនុសាសន៍ជូនរដ្ឋមន្ត្រីអំពីការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃស្តង់ដារសម្រាប់ ផលិតផល ដំណើរការ ការអនុវត្ត ការធ្វើតេស្ត និងសេវាកម្ម និងសម្រេចយល់ព្រមលើកម្មវិធី ផែនការ គម្រោង និងសកម្មភាពនានា សំដៅជំរុញប្រសិទ្ធភាព និងការអភិវឌ្ឍឧស្សាហកម្ម និងសម្រាប់ការពារអ្នកប្រើប្រាស់តាមរយៈសកម្មភាពស្តង់ដានីយកម្ម។

ច- ណែនាំវិទ្យាស្ថានអំពីលក្ខណវិនិច្ឆ័យនិងនីតិវិធីដែលទាក់ទងនឹងការរៀបចំការសម្រេចយល់ព្រម ការទទួលយក និងការជ្រើសរើសស្តង់ដារ។

ឆ- រៀបចំបទបញ្ជាផ្ទៃក្នុង សម្រាប់ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សា។

ជ- បំពេញមុខងារដទៃទៀតទៅតាមការកំណត់ឬតាមការប្រគល់សិទ្ធិរបស់រដ្ឋមន្ត្រី។

## ជំពូកទី៤ ថ្មី

## ស្តង់ដារកម្ពុជានិងបទប្បញ្ញត្តិបច្ចេកទេស

**មាត្រា១៦ ._ថ្មី**

ក្នុងគោលបំណងធានាឲ្យមានសុវត្ថិភាពពិតប្រាកដ ដើម្បីបង្ការភាពមហន្តរាយដែលប៉ះពាល់ជាសាធារណៈឬប៉ះពាល់ដល់វិស័យឧស្សាហកម្មឬសេដ្ឋកិច្ចជាតិ ប្រភេទនៃផលិតផលឬប្រព័ន្ធណាមួយ ត្រូវអនុលោមទៅតាមស្តង់ដារណាមួយជាកំណត់ ហើយស្តង់ដារនោះត្រូវកំណត់ជាបទប្បញ្ញត្តិបច្ចេកទេស តាមការស្នើរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងតាមការសម្រេចរបស់ក្រុមប្រឹក្សា។

ការកំណត់បទប្បញ្ញត្តិបច្ចេកទេសត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រី ហើយកាលបរិច្ឆេទចូលជាធរមានមិនត្រូវឲ្យតិចជាង៦(ប្រាំមួយ)ខែ ចាប់ពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាស។

លើកលែងតែក្នុងករណីបន្ទាន់ពាក់ព័ន្ធនឹងសុវត្ថិភាព សុខភាព ការការពារបរិស្ថាន ឬបញ្ហាសន្តិសុខជាតិកើតឡើងឬដែលអាចនឹងកើតឡើង ត្រូវប្រកាសផ្សាយភ្លាមៗអំពីបទប្បញ្ញត្តិបច្ចេកទេសពិសេសនិងផលិតផលដែលគ្របដណ្តប់ដោយបទប្បញ្ញត្តិបច្ចេកទេសនោះ ជាមួយនឹងសេចក្តីពន្យល់សង្ខេបនៃកម្មវត្ថុនិងគោលបំណងនៃបទប្បញ្ញត្តិបច្ចេកទេសនោះ ដោយរួមបញ្ចូលទាំងប្រភេទនៃបញ្ហាបន្ទាន់ផងដែរ។

**មាត្រា១៩ .-ថ្មី**

ក្រសួង ស្ថាប័ន ឬអង្គការពាក់ព័ន្ធណាមួយ អាចធ្វើសំណើទៅក្រុមប្រឹក្សា ដើម្បីសុំបង្កើតស្តង់ដារកម្ពុជា ឬកំណត់បទប្បញ្ញត្តិបច្ចេកទេសជាក់លាក់មួយ។ ប្រសិនបើក្រុមប្រឹក្សាយល់ថា មិនជាការចាំបាច់ទេនោះ ក្រុមប្រឹក្សាត្រូវបញ្ជាក់ពីមូលហេតុនិងជូនដំណឹងទៅក្រសួង ស្ថាប័ន ឬអង្គការពាក់ព័ន្ធនោះវិញ។

ក្រុមប្រឹក្សាស្តង់ដារជាតិត្រូវពិនិត្យស្តង់ដារកម្ពុជាឬបទប្បញ្ញត្តិបច្ចេកទេសជារៀងរាល់៥(ប្រាំ)ឆ្នាំម្តង។

ការធ្វើវិសោធនកម្ម ការព្យួរទុក ឬការលុបចោលស្តង់ដារឬបទប្បញ្ញត្តិបច្ចេកទេស ក្រុមប្រឹក្សាត្រូវអនុវត្តដោយឈរលើមូលដ្ឋាននៃការពិនិត្យឡើងវិញតាមការស្នើសុំរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ។

**មាត្រា២៦ .-ថ្មី**

នៅពេលដែលបទប្បញ្ញត្តិបច្ចេកទេសមួយត្រូវប្រកាសដូចមានចែងក្នុងមាត្រា១៦ថ្មីនៃច្បាប់នេះ និងក្រោយកាលបរិច្ឆេទចូលជាធរមានដែលបានកំណត់បញ្ជាក់ក្នុងប្រកាសនោះ ការផលិតឬការបន្តផលិតនូវផលិតផលណាមួយ ឬការរៀបចំខ្សែចង្វាក់ផលិតកម្មណាមួយ ឬផលិតផលនាំចូលណាមួយ ត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសនោះ។

**មាត្រា៥០.១ .-ថ្មី**

ទណ្ឌកម្មក្នុងច្បាប់នេះរួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរ ឬការដកហូត ឬការលុបចោលវិញ្ញាបនបត្របញ្ជាក់ផលិតផលឬវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធឬអាជ្ញាបណ្ណ ការពិន័យអន្តរការណ៍ ទោសពិន័យជាប្រាក់ និងទោសដាក់ពន្ធនាគារ។

**មាត្រា៥០.២ .-ថ្មី**

ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរ ឬការដកហូត ឬការលុបចោលវិញ្ញាបនបត្របញ្ជាក់ផលិតផលឬវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធឬអាជ្ញាបណ្ណជាសមត្ថកិច្ចរបស់វិទ្យាស្ថាន។

ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ច។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា៥០.៣ ._ថ្មី**

ការពិន័យជាប្រាក់ដែលមានចែងចាប់ពីមាត្រា៥០ថ្មីដល់មាត្រា៥៨ថ្មីនៅក្នុងជំពូកនេះ អាចត្រូវបានអនុវត្តជាពិន័យអន្តរការណ៍ ដោយមន្ត្រីអធិការកិច្ច។ ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឲ្យរលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចត្រូវកសាងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការតាមនីតិវិធី។

ក្នុងករណីដែលមិនស្គាល់អត្តសញ្ញាណរបស់ជនល្មើស មន្ត្រីអធិការកិច្ចត្រូវស្នើសុំព្រះរាជអាជ្ញាមានសមត្ថកិច្ច ដើម្បីរឹបអូសវត្ថុតាងនៃបទល្មើសយកទៅបំផ្លាញចោលឬទុកជាសម្បត្តិរដ្ឋ។ ជនដែលមានប្រយោជន៍ពាក់ព័ន្ធមានសិទ្ធិប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាទៅតុលាការរដ្ឋប្បវេណី។

នីតិវិធីនិងសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសដូចមានចែងក្នុងច្បាប់នេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី។

**មាត្រា៥០.៤ ._ថ្មី**

ប្រាក់ពិន័យអន្តរការណ៍ ប្រាក់ពិន័យតាមសាលក្រមឬសាលដីការបស់តុលាការ ឬប្រាក់បានមកពីការលក់វត្ថុតាងដែលតុលាការសម្រេចរឹបអូសជាសម្បត្តិរដ្ឋ ត្រូវបង់ចូលថវិកាជាតិ។ រាជរដ្ឋាភិបាលអាចសម្រេចផ្តល់ជារង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសជាក់លាក់ណាមួយដែលមានចែងក្នុងច្បាប់នេះ។

**មាត្រា៥០.៥ ._ថ្មី**

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរ ការដកហូត ឬការលុបចោលវិញ្ញាបនបត្របញ្ជាក់ផលិតផលឬវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធឬអាជ្ញាបណ្ណ ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើដូចខាងក្រោម៖

១- អ្នកកាន់វិញ្ញាបនបត្របញ្ជាក់ផលិតផល ឬវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ ឬអាជ្ញាបណ្ណ រំលោភទៅនឹងបញ្ញត្តិនៃច្បាប់នេះ ឬបទបញ្ជាដែលក្រសួងបានចេញស្របតាមច្បាប់នេះ ឬលក្ខខណ្ឌដែលបានដាក់ជាបញ្ញត្តិដោយវិទ្យាស្ថាន ឬរកឃើញថាផលិតផលឬប្រព័ន្ធគ្រប់គ្រងមិនអនុលោមទៅតាមស្តង់ដារដែលបានកំណត់។

២- អនុវត្តខុសធ្ងន់ធ្ងរទៅនឹងការតម្រូវនៃលក្ខខណ្ឌនៃការផ្តល់និងការប្រើប្រាស់វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ឬសញ្ញាស្តង់ដារ។

៣- ធ្វើការផ្សាយពាណិជ្ជកម្មផ្ទុយនឹងវិធានឬលក្ខខណ្ឌតម្រូវនៃការផ្តល់និងការប្រើប្រាស់វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ឬសញ្ញាស្តង់ដារ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

៤- ផ្ទេរសិទ្ធិកាន់កាប់វិញ្ញាបនបត្រឬអាជ្ញាបណ្ណ ទៅឲ្យតតិយជនដោយគ្មានការយល់ព្រមជាមុនពីវិទ្យាស្ថាន។

**មាត្រា៥០.៦ .-ថ្មី**

ត្រូវទទួលពិន័យអន្តការណ៍ជាប្រាក់មិនលើសពី ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលណាដែលប្រើប្រាស់ពាណិជ្ជសញ្ញាដែលដូចគ្នានឹងសញ្ញាស្តង់ដារដែលបានប្រកាសស្របតាមមាត្រា២០នៃច្បាប់នេះ ឬប្រើប្រាស់ពាណិជ្ជសញ្ញាដែលស្ទើរតែដូចគ្នាទាំងស្រុងធ្វើឲ្យច្រឡំគ្នាទៅនឹងសញ្ញាស្តង់ដារ។

**មាត្រា៥១ .-ថ្មី**

ត្រូវទទួលពិន័យជាប្រាក់មិនលើសពី ២ ០០០ ០០០(ពីរលាន)រៀល ចំពោះបុគ្គលណាដែលមិនបានដាក់តាំងអាជ្ញាបណ្ណរបស់ខ្លួននៅកន្លែងដែលអាចមើលឃើញច្បាស់នៅក្នុងទីតាំងផលិតដែលបានបញ្ជាក់ក្នុងអាជ្ញាបណ្ណ ឬមិនបានសុំអាជ្ញាបណ្ណទុតិយតាពីវិទ្យាស្ថានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលបានដឹងឮជាសាធារណៈ អំពីអាជ្ញាបណ្ណរបស់ខ្លួនត្រូវបាត់បង់ ឬខូចខាតទាំងស្រុង ឬមិនបានសុំអាជ្ញាបណ្ណថ្មីពីវិទ្យាស្ថាន មុនដំណើរការផលិតនៅពេលមានការផ្លាស់ប្តូរទីតាំងផលិត ឬបង្កើតសាខា ឬពង្រីកផលិតកម្ម។

**មាត្រា៥២ .-ថ្មី**

ត្រូវទទួលពិន័យជាប្រាក់មិនលើសពី២ ០០០ ០០០(ពីរលាន)រៀល ចំពោះបុគ្គលណាដែលបញ្ចូលទៅក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាអំពីការទទួលវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធណាមួយដែលមិនបានចុះបញ្ជីនិងបានទទួលទិដ្ឋាការពីវិទ្យាស្ថានស្តង់ដារ។

**មាត្រា៥៣ .-ថ្មី**

ត្រូវទទួលពិន័យជាប្រាក់មិនលើសពី២ ០០០ ០០០(ពីរលាន)រៀល ចំពោះបុគ្គលណាដែលធ្វើអាជីវកម្មដោយប្រើឈ្មោះដែលមានពាក្យ **ស្តង់ដារកម្ពុជា** ឬ អក្សរកាត់ ISC។

**មាត្រា៥៤ .-ថ្មី**

ត្រូវទទួលពិន័យជាប្រាក់មិនលើសពី៥ ០០០ ០០០(ប្រាំលាន)រៀល ចំពោះអ្នកកាន់អាជ្ញាបណ្ណដែលមានប្រើសញ្ញាស្តង់ដារ ដោយអនុលោមតាមស្តង់ដារចាស់មិនបានសុំការអនុញ្ញាតពីវិទ្យាស្ថាន ឬប្រើហួសកាលបរិច្ឆេទកំណត់របស់វិទ្យាស្ថាននៅពេលមានការកំណត់ស្តង់ដារថ្មីមួយ ឬក៏មានការកែប្រែស្តង់ដារណាមួយ។

**មាត្រា៥៥ .-ថ្មី**

ត្រូវទទួលពិន័យជាប្រាក់មិនលើសពី ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលណាដែលផលិត កែច្នៃ នាំចូលផលិតផល ឬផ្សព្វផ្សាយពាណិជ្ជកម្មលក់ ឬលក់ផលិតផលណាមួយ ដែលមាន

បិទសញ្ញាស្តង់ដារក្លែងបន្លំក្នុងបំណងបំភាន់សាធារណជនឲ្យជឿថាផលិតផលរបស់ខ្លួនមានអាជ្ញាបណ្ណ និងបានអនុលោមតាមស្តង់ដារកម្ពុជា។

**មាត្រា៥៦ ._ថ្មី**

ត្រូវទទួលពិន័យជាប្រាក់មិនលើសពី ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលណាដែលផ្សព្វផ្សាយឬប្រើប្រាស់វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធឬសញ្ញាបញ្ជាក់ប្រព័ន្ធណាមួយក្លែងបន្លំក្នុងគោលបំណងបំភាន់សាធារណជនឲ្យជឿថាប្រព័ន្ធរបស់ខ្លួនមានវិញ្ញាបនបត្រ។

**មាត្រា៥៧ ._ថ្មី**

ត្រូវទទួលពិន័យជាប្រាក់មិនលើសពី ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលណាដែលផ្សព្វផ្សាយឬប្រើប្រាស់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ឬវិញ្ញាបនបត្រចុះបញ្ជីក្លែងបន្លំ ក្នុងគោលបំណងបំភាន់សាធារណជនឲ្យជឿថាបុគ្គលឬអង្គភាពរបស់ខ្លួនបានទទួលការវាយតម្លៃទទួលស្គាល់ឬបានចុះបញ្ជី។

**មាត្រា៥៨ ._ថ្មី**

ត្រូវទទួលពិន័យជាប្រាក់មិនលើសពី ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលណាដែលបោះពុម្ពឬថតចម្លងឯកសារស្តង់ដារកម្ពុជា ដោយមិនបានមានការអនុញ្ញាតពីវិទ្យាស្ថាន។

**មាត្រា៥៩ ._ថ្មី**

បុគ្គលណាមួយដែលផលិត ឬកែច្នៃ ឬនាំចូលផលិតផល ឬផ្សព្វផ្សាយពាណិជ្ជកម្មលក់ ឬលក់ផលិតផលណាមួយដែលមានស្តង់ដារប្រភេទបទប្បញ្ញត្តិបច្ចេកទេសដែលបានប្រកាសដូចមានចែងក្នុងមាត្រា១៦ថ្មីនៃច្បាប់នេះ និងក្រោយកាលបរិច្ឆេទចូលជាធរមានដែលបានកំណត់បញ្ជាក់ក្នុងប្រកាសនោះរួចហើយ មិនមានបិទសញ្ញាស្តង់ដារ ឬគ្មានអាជ្ញាបណ្ណ ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសនោះ ត្រូវទទួលការផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែដល់១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ចំនួនពី២ ០០០ ០០០(ពីរលាន)រៀលទៅ ២៤ ០០០ ០០០(ម្ភៃបួនលាន)រៀល ឬទោសណាមួយនៃទោសទាំងពីរ។

**មាត្រា៦៥ ._ថ្មី**

ជនណាដែលរារាំងមន្ត្រីអធិការកិច្ចក្នុងពេលបំពេញភារកិច្ចត្រូវពិន័យជាប្រាក់ចំនួនពី១ ០០០ ០០០(មួយលាន)រៀលទៅ៥ ០០០ ០០០(ប្រាំលាន)រៀល។

**មាត្រា៦៦ ._ថ្មី**

ជនណាមួយដែលក្លែងបន្លំខ្លួនជាមន្ត្រីអធិការកិច្ចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ដល់១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ចំនួនពី៥០០ ០០០(ហាសិបម៉ឺន)រៀលទៅ២ ០០០ ០០០(ពីរលាន)រៀល ឬទោសណាមួយនៃទោសទាំងពីរ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា៦៧ ._ថ្មី**

មន្ត្រីអធិការកិច្ចដែលមានចែងក្នុងមាត្រា៧ថ្មីនៃច្បាប់នេះ ត្រូវទទួលខុសត្រូវចំពោះទណ្ឌកម្ម រដ្ឋបាល។

មន្ត្រីអធិការកិច្ចត្រូវទទួលខុសត្រូវចំពោះការធ្វេសប្រហែសដែលបណ្ដោយឲ្យមានការជ្រៀតជ្រែក បទល្មើសផ្សេងៗ ... 

ទណ្ឌកម្មរដ្ឋបាលដែលមានចែងខាងលើនេះមិនធ្វើជាឧបសគ្គដល់ការធ្វើបណ្ដឹងអាជ្ញាឡើយ ប្រសិនបើមានបទល្មើសណាមួយត្រូវប្រព្រឹត្ត។

**មាត្រា៦៨ ._ថ្មី**

ទណ្ឌកម្មរដ្ឋបាលដែលត្រូវអនុវត្តចំពោះមន្ត្រីអធិការកិច្ចរួមមាន៖

ក- ទណ្ឌកម្មរដ្ឋបាលកម្រិតដំបូង គឺការព្រមានឬការស្ដីបន្ទោសពីអគ្គនាយក។

ខ- ទណ្ឌកម្មរដ្ឋបាលកម្រិតមធ្យម គឺការបញ្ឈប់ការផ្ដល់ប្រាក់បៀវត្សនិងអត្ថប្រយោជន៍ផ្សេងៗទៀត ក្នុងរយៈពេលចាប់ពី៦(ប្រាំមួយ)ខែឡើងទៅ។

គ- ទណ្ឌកម្មរដ្ឋបាលកម្រិតធ្ងន់ គឺការដកហូតតួនាទីឬមុខតំណែង ឬការបញ្ឈប់ពីការងារតែម្ដង។

ទណ្ឌកម្មរដ្ឋបាលដែលមានចែងខាងលើនេះនៅពុំទាន់គិតដល់បទល្មើសព្រហ្មទណ្ឌនិងសំណង រដ្ឋប្បវេណីផ្សេងៗទៀត។

**មាត្រាពីរ ._**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃ អង្គារ ១៤កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៨

នសរកម.១៨០៦.៦៦៤

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ដលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**ហត្ថលេខា**
**កិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ**

លេខ:៦៧៨ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃព្រហស្បតិ៍ ១រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ,ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**